# កូវីដ-១៩និងការលក់ចំណីអាហារក្នុងរាជធានីភ្នំពេញ

ដោយ បណ្ឌិត ព្រុំ ទេវី
អនុប្រធានវិទ្យាស្ថានសង្គមសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

ជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ (Coronavirus Disease: COVID-19) បានកើតជាដំបូងនៅប្រទេសចិន នាខែធ្នូ ឆ្នាំ២០១៩ បន្ទាប់មកបានសាយភាយដល់ប្រទេសជាច្រើនក្នុងពិភពលោក។ នាពាក់កណ្ដាលខែមីនា ឆ្នាំ២០២០នេះ ប្រទេសចិនមិនមែនជាចំណុចក្ដៅនៃជំងឺនេះទៀតទេ គឺនៅអឺរ៉ុបនិងសហរដ្ឋអាម៉េរិទៅវិញ។ គិតមកត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០នេះ សហរដ្ឋអាម៉េរិក មាន ១៦៤ ៣៥៩(ស្លាប់៣ ១៧៣នាក់) អ៊ីតាលី ១០១ ៧៣៩ករណី (ស្លាប់១១ ៥៩១នាក់) ចិន ៨១ ៥១៨ករណី(ស្លាប់ ៣ ៣០៥នាក់)។ នៅកម្ពុជាមានករណីវិជ្ជមានសរុប ១០៩នាក់ ក្នុងនោះ ២៣នាក់ បានជាសះស្បើយហើយ។

ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19 ប្រមុខរាជរដ្ឋាភិបាលកម្ពុជារួមជាមួយនឹងស្ថាប័នជំនាញបានចេញសេចក្ដីជូនដំណឹងជាបន្តបន្ទាប់ ដើម្បីផ្អាកមិនឱ្យដំណើរការទៅទីកន្លែងដែលមានការប្រមូលផ្ដុំមនុស្សច្រើន ក៏ដូចជាហាមឃាត់ជនបរទេសមកពីប្រទេសមួយចំនួន។ ក្រៅពីនោះ ក៏មានការសម្រេចបិទច្រកព្រំដែនជាមួយប្រទេសជិតខាង តែរក្សាការឆ្លងកាត់ទំនិញឱ្យនៅដដែល។ ចំពោះផ្សារ ភោជនីយដ្ឋាន ហាងកាហ្វេ នៅក្នុងរាជធានីភ្នំពេញនៅបើកដំណើរការធម្មតា តែទោះជាយ៉ាងណាក៏ដោយអាជីវកម្មខ្លះហាក់ដូចជាប្រព្រឹត្តទៅធម្មតា មួយចំនួនមានសកម្មភាពកាន់តែច្រើនជាងមុន ទន្ទឹមគ្នានឹងមួយចំនួនទៀតត្រូវផ្អាកសកម្មភាពជាស្ថាពរ។

ការធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើគិតតាមទីតាំង គេអាចបែងចែកដូចជាអាជីវកម្មតាមចិញ្ចើមថ្នល់ (street business) តាមផ្ទះ (home business) តាមផ្ទះល្វែង (business in apartment building) តាមផ្សារប្រពៃណី (business in traditional market) ជាដើម។ អាជីវកម្មតាមចិញ្ចើមថ្នល់ សំដៅដល់ការលក់ដូរទំនិញ ឬផ្ដល់សេវាដោយមានតូបតាមចិញ្ចើមថ្នល់ ឬនៅជុំវិញផ្សារ។ ការលក់ដូរតាមផ្ទះ សំដៅលើអាជីវកម្មដែលធ្វើឡើងនៅតាមផ្ទះរបស់អាជីវករ រីឯអាជីវកម្មតាមផ្សារប្រពៃណីវិញ សំដៅដល់ការលក់ដូរក្នុងផ្សារទាំងមានទាំងពុំមានការអនុញ្ញាតិពីប្រធានផ្សារ។ អត្ថបទនេះនឹងបង្ហាញពីស្ថានភាពនៃការលក់ចំណីអាហារនៅទីក្រុងភ្នំពេញកំលុងពេលនៃការរីករាលដាលនៃជំងឺ COVID-19 ក្នុងខែមីនា ឆ្នាំ២០២០ ដោយឆ្លុះបញ្ចាំងទៅតាមទីតាំងផ្សេងៗនៃការលក់ដូរ។

នៅក្នុងប្រទេសកម្ពុជា ដូចជាជាបណ្តាប្រទេសផ្សេងទៀតក្នុងពិភពលោកដែរ ចំនួនអង្គភាពអាជីវកម្មតាមចិញ្ចើមថ្នល់មានការកើនឡើង ព្រោះជាប្រភពផលចំណូលយ៉ាងសំខាន់សម្រាប់គ្រួសារក្រីក្រ។ អាជីវករលក់ទំនិញជាសាធារណៈដោយពុំមានទីតាំងក្នុងសំណង់អចិន្ត្រៃយ៍ណាមួយ ហើយយកទីតាំងលើចិញ្ចើមថ្នល់ កន្លែងសាធារណៈ ឬឯកជនណាមួយដើម្បីលក់ទំនិញ ឬផ្តល់សេវា។

ការលក់តាមចិញ្ចើមថ្នល់ មានសារសំខាន់ណាស់សម្រាប់ជីវភាពរបស់គ្រួសារក្រីក្រ គេលក់ភាគច្រើនប្រើពេលពី ៨ ទៅ ១៣ម៉ោងក្នុង១ថ្ងៃ ហើយ ៧ថ្ងៃក្នុងមួយសប្តាហ៍។



ប្រភព៖ អ៊ីនធឺណិត

មុខទំនិញដែលគេដាក់តាមចិញ្ចើមថ្នល់ ភាគច្រើនជាអាហារឆ្អិនស្រាប់ ឬអាហារសម្រន់ដែលអតិថិជនអាចបរិភោគនៅកន្លែងលក់ ឬខ្ចប់យកតាមខ្លួនបាន ហើយផ្តល់លក្ខណៈងាយស្រួលដល់អ្នកមិនមានពេលគ្រប់គ្រាន់សម្រាប់ចម្អិនអាហារ។ អាហារតាមចិញ្ចើមថ្នល់ (street food) នៅទីក្រុងភ្នំពេញមានក្នុងតម្លៃគ្រប់កម្រិតសម្រាប់អតិថិជន។ អាជីវកម្មដូចក្នុងរូបភាពខាងលើ តម្លៃមិនសូវថ្លៃទេ សមស្របសម្រាប់អ្នកមានចំណូលតិច រីឯអ្នកមានចំណូលមធ្យម គេអាចទទួលអាហារដែលដាក់លក់ជាអាជីវកម្មតាមផ្ទះ (home business) ឬតាមផ្ទះល្វែង (business in apartment building)។

ការលក់អាហារតាមបែបអាជីវកម្មទាំង ៣ប្រភេទខាងលើនេះ ទទួលបានអតិថិជនភាគច្រើនជាអ្នកធ្វើការតាមស្ថាប័ននានា រួមទាំងកម្មករសំណង់ផងដែរ។ កំលុងពេលដែលរាជរដ្ឋាភិបាលតម្រូវឱ្យការជួបប្រជុំមនុស្សច្រើនផ្អាកជាបណ្តោះអាសន្ន ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19 អាជីវកម្មប្រភេទនេះ ជាពិសេសនៅជិតកន្លែងធ្វើការនានាក៏ត្រូវផ្អាកដែរ។ បញ្ហាគឺត្រង់ថា អ្នកលក់តាម

ចិញ្ចើមផ្ទាល់ជាអ្នកមានដើមទុនតិច ផលចំណេញប្រចាំថ្ងៃមិនជាច្រើនប៉ុន្មានទេ ការផ្អាកលក់ដូរឃ្យូរ អាចឱ្យគាត់មានបញ្ហាក្នុងការចិញ្ចឹមជីវិត។




ប្រភព៖ អ៊ីនធឺណិត

កន្លែងដែលធ្លាប់មានមនុស្សច្រើនកុះករមកបរិភោគអាហារបន្តិចបន្តួចនៅកោះពេជ្រ នាខែមីនា ឆ្នាំ២០២០នេះ មានសភាពស្ងប់ស្ងាត់។



ប្រភព៖ អ្នកនិពន្ធ



ប្រភព៖ អ្នកនិពន្ធ

អាជីវកម្មក្នុងផ្សារប្រពៃណី (business in traditional market) មានការប្រព្រឹត្តទៅជាធម្មតា ព្រោះរាជរដ្ឋាភិបាលមិនទាន់មានចេញសេចក្តីប្រកាសឱ្យបិទទេ។ *"ផ្សារនិងកន្លែងលក់ដូរ យើងមានតែលើកទឹកចិត្ត ឱ្យពួកគាត់បន្តការលក់ដូរ ដើម្បីឱ្យប្រជាពលរដ្ឋរបស់យើង អាចបន្តជីវភាពប្រចាំថ្ងៃបាន ប្រសិនបើយើងផ្អាកផ្សារ យើងទៅរកអ្វីហូបនៅឯណា? នេះជាបញ្ហាដែលយើងត្រូវគិតគូរដូច្នេះហើយ យើងនៅតែលើកទឹកចិត្តឱ្យផ្សារត្រូវតែនៅដំណើរការ"* ប្រសាសន៍លោក ឃួង ស្រេង កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០។ ឆ្លើយតបនឹងការទប់ស្កាប់នៃការរីករាលដាលនៃជំងឺ COVID-19 គណៈកម្មការផ្សារ បានចាត់ចែងលាងសម្អាតផ្សារ រៀបចំតាមច្រកចេញចូលរបស់ផ្សារនីមួយៗ សុទ្ធតែដាក់អាល់កុលដើម្បីឱ្យប្រជាពលរដ្ឋ ក៏ដូចជាអាជីវករបានលាងដៃ។ ថ្វីបើផ្សារប្រពៃណីបើកឱ្យដំណើរការធម្មតាក៏ពិតមាន តែមិនមានអតិថិជនពេញលេញដូចកាលពីមុនទេ។ អ្នកទៅផ្សារភាគច្រើនទិញតែម្ហូបចាំបាច់សម្រាប់ការរស់នៅប្រចាំថ្ងៃ អាចនិយាយថាដូចធម្មតា ព្រោះមិនមានការដណ្តើមគ្នាទិញសម្រាប់យកមកស្តុកទុកអ្វីទេ តែទំនិញមិនចាំបាច់ប្រចាំថ្ងៃមិនសូវមានអតិថិជនទេ។




ប្រភព៖ https://freshnewsasia.com/index.php/en/localnews/152257-2020-03-21-06-56-10.html

ដកស្រង់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០។



ប្រភព៖ https://freshnewsasia.com/index.php/en/localnews/152257-2020-03-21-06-56-10.html

ដកស្រង់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០។

ខាងក្រោមនេះជារូបភាពក្នុងភោជនីយដ្ឋានរបស់សណ្ឋាគារទំនើបមួយនៅទីក្រុងភ្នំពេញ ថត នៅក្នុងខែមីនា ឆ្នាំ២០២០។ ដើម្បីជាសុវត្ថិភាពរបស់អតិថិជន គេរៀបរបាំងសម្រាប់អតិថិជនម្នាក់ៗ

ហើយតុនីមួយៗមានគម្លាតពីគ្នាយ៉ាងតិច ១,៥ម៉ែត្រ។ តែទោះជាយ៉ាងណាក៏ដោយ អតិថិនរបស់ភោជនីយដ្ឋាននេះ ថយចុះប្រមាណជា ៨០%។



ប្រភព៖ អ្នកនិពន្ធ

អាហារដ្ឋានសម្រាប់បុគ្គលិកនៅសណ្ឋាគារមួយ ក៏បានរៀបចំឱ្យមានរបាំងដែរ ដើម្បីសុវត្ថិភាពរបស់បុគ្គលិកដែរ។



ប្រភព៖ អ៊ីនធឺណិត

នៅមានអាជីវកម្មមួយប្រភេទទៀត ដែលពិបាកនឹងធ្វើស្ថិតិ ហើយមានចំនួនច្រើននៅទីក្រុងភ្នំពេញ។ កន្លែងជាអគារជាក់លាក់សម្រាប់លក់អាហារនៅទីក្រុងភ្នំពេញមិនអត់ទេតែសម្រាប់អ្នកដែលមានដើមទុនតិចតួចប្រាកដជាមិនអាចជួលបាន ម៉្លោះហើយរទេះជាមធ្យោបាយសំខាន់បំផុត។



ប្រភព៖ អ៊ីនធឺណិត

អាហារដែលដាក់លក់តាមរទេះមានដូចជាបាយសាច់ជ្រូក នំបញ្ចុក ភេសជ្ជៈ ផ្លែឈើ ឪមសាំ ជាដើម។ អាជីវកម្មប្រភេទនេះ មាន ២ប្រភេទ មួយជាលក្ខណៈក្រុមហ៊ុន មានរទេះច្រើន ដែលអ្នកលក់ទទួលប្រាក់ឧបត្ថម្ភពីប្រធានក្រុមហ៊ុន និងមួយទៀតអ្នកលក់ជាម្ចាស់លើរទេះតែម្តង។ អតិថិជនរបស់អាជីវកម្មប្រភេទនេះ ស្ទើរតែទាំងអស់ជាអ្នកមានចំណូលតិច។ ក្រៅពីការលក់តាមដងផ្លូវពេលខ្លះក៏ពួកគេក៏មានកន្លែងសំចតខ្លះដែរ ភាគច្រើនគេរកកន្លែងដែលមានមនុស្សច្រើន ជិតផ្សារ កន្លែងធ្វើការ ការដ្ឋានសំណង់។ល។




ប្រភព៖ អ៊ីនធឺណិត

នាចុងខែមីនា ឆ្នាំ២០២០នេះ នៅតាមដងផ្លូវ ពុំឃើញមានរទេះលក់ជារបស់ក្រុមហ៊ុនទេ តែនៅមានរទេះលក់ជាបុគ្គលខ្លះៗដែរ។ ភាគច្រើននៃអ្នកទាំងនោះអះអាងថា ខ្លាចឆ្លងជំងឺCOVID-19 តែបើមិនលក់ មិនមានអ្វីចិញ្ចឹមកូនៗរបស់គេ។

ជាដំណោះស្រាយក្នុងពេលដ៏លំបាកនេះ នៅប្រទេសឥណ្ឌា គេបានរៀបចំឱ្យពលរដ្ឋរក្សាចម្ងាយពីគ្នានៅពេលទិញដូរទំនិញ តែយើងមិនអាចដឹងបានដែរថា ដំណោះស្រាយបែបនេះមានប្រសិទ្ធភាពយ៉ាងណាដែរ។



ប្រភព៖ អ៊ីនធឺណិត

ក្នុងខណៈពេលដែលរាជរដ្ឋាភិបាលកាត់បន្ថយការជួបជុំគ្នាច្រើន ការលក់ម្ហូបអាហារដែលតម្រូវឱ្យអតិថិជនទៅរកអ្នកផ្គត់ផ្គង់តាមបែបលក់តាមចិញ្ចើមថ្នល់ (street business) តាមផ្ទះ (home business) តាមផ្ទះល្វែង (business in apartment building) តាមផ្សារប្រពៃណី (business in traditional market) ឬក៏នៅក្នុងកន្លែងទំនើបណាមួយ សុទ្ធតែមានការលំបាកនឹងទទួលបានអតិថិជន ព្រោះម្នាក់ៗត្រូវនៅក្នុងផ្ទះដើម្បីការពារកុំឱ្យឆ្លងជំងឺCOVID-19។ ដូចគ្នាដែរចំពោះការលក់តាមរទេះ ទាំងជារបស់ក្រុមហ៊ុន ទាំងជារបស់បុគ្គល គឺជារបៀបដែលអ្នកផ្គត់ផ្គង់ស្វែងរកអ្នកមានតម្រូវការ។ វិធីសាស្ត្រទាំងពីរនេះ អ្នកមានតម្រូវការស្វែងរកអ្នកផ្គត់ផ្គង់ និង អ្នកផ្គត់ផ្គង់ស្វែងរកអ្នកមានតម្រូវ សុទ្ធតែត្រូវចំណាយពេលតាមទីសាធារណៈទាំងអស់ ពេលគឺអ្នកទាំងនោះងាយនឹងឆ្លងជំងឺជាងអ្នកនៅក្នុងផ្ទះ។




ប្រភព៖ អ្នកនិពន្ធ

ដើម្បីចៀសវាងការឆ្លងជំងឺCOVID-19 អ្នកផ្គត់ផ្គង់ ក៏ដូចជាអ្នកមានតម្រូវការ គួរប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ដើម្បីចំណេញពេលផង និងចៀសវាងការធ្វើដំណើរទៅទីសាធារណៈផង។ ខុសពីវិធីសាស្ត្រ ដែលបានបង្ហាញទាំងប៉ុន្មានខាងលើ អ្នកផ្គត់ផ្គង់ចាំបាច់ត្រូវបង្ហាញមុខទំនិញផ្សេងៗតាមប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា Facebook Instagram Messenger ជាដើម រួមទាំងតម្លៃ និងវិធីសាស្ត្រទូទាត់ផងដែរ។ អ្នកមានតម្រូវការអាចធ្វើការជ្រើសរើសមុខទំនិញឬប្រភេទអាហារដែលចង់បាន ហើយធ្វើការទំនាក់ទំនងទៅអ្នកផ្គត់ផ្គង់ តាមរយៈទូរសព្ទឬប្រព័ន្ធផ្សព្វផ្សាយសង្គម។ អ្នកមានតម្រូវការរង់ចាំទទួលទំនិញពីអ្នកដឹកជញ្ជូននិងទូទាត់ជាការស្រេច។




ប្រភព៖ អ្នកនិពន្ធ

ការលក់ដូរដោយប្រើប្រព័ន្ធផ្សព្វផ្សាយសង្គម ពិតជាមានភាពងាយស្រួលជាងការដែលអ្នកផ្គត់ផ្គង់ ឬអ្នកមានតម្រូវការ ស្វែងរកគ្នាតាមទីសាធារណៈ។ ក្នុងន័យនេះ អ្នកផ្គត់ផ្គង់ត្រូវចេះប្រើប្រព័ន្ធ

ផ្សព្វផ្សាយសង្គម ដើម្បីបង្ហាញនូវមុខទំនិញរបស់ខ្លួន រីឯអ្នកមានតម្រូវការក៏ត្រូវចេះប្រើដូចគ្នាដែរ ដើម្បីជ្រើសរើសមុខទំនិញដែលត្រូវការ។

## គន្ថនិទ្ទេស


១- International Labor Office: On the Border of Legality, A Review of Studies on Street vending in Phnom Penh Cambodia, Bangkok, 2006

២- Kyoko Kusakabe: Policy Issues on Street Vending: An Overview of Studies in Thailand, Cambodia and Mongolia,Bangkok, International Labor Office, 2006

៣-National Institute of Statistics, Ministry of Planning: Economic Census of Cambodia 2011, Phnom Penh, 2012។

៤-National Institute of Statistics, Ministry of Planning: Economic Census of Cambodia 2011, Provincial Report, 12 Phnom Penh Municipality, Phnom Penh, 2012.

៥-https://www.worldometers.info/coronavirus/. Accessing on 31 March 2020.

៦- https://dap-news.com/national/2020/03/25/43855/ ដកស្រង់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០។

៧- https://freshnewsasia.com/index.php/en/localnews/152257-2020-03-21-06-56-10.html ដកស្រង់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០។